**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសវនកម្មជាតិ**

លេខ:..................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅរដ្ឋបាលក្រុងព្រៃវែង រដ្ឋបាលស្រុកពាមរក៍ រដ្ឋបាលស្រុកស្វាយអន្ទរ និងរដ្ឋបាលស្រុកកំពង់ត្របែកនៃខេត្តព្រៃវែង

**ការិយបរិច្ឆេទ២០២៥**

អគារលេខ ៥ ផ្លូវឡុងរៀបព៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

# 5, St Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA

Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900

E-mail: naakh@naa.gov.kh website: www.naa.gov.kh

## សេចក្តីសង្ខេប

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានជ្រើសយករដ្ឋបាលខេត្តព្រៃវែងដោយគ្របដណ្តប់លើរដ្ឋបាលក្រុង-ស្រុកទាំង៣ ដើម្បីធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនសម្រាប់ការិយបរិច្ឆេទ២០២៥ និងឆ្នាំពាក់ព័ន្ធ។

បច្ចុប្បន្ននេះ ខេត្តព្រៃវែងមានក្រុង-ស្រុកចំនួន១៣ ដោយឡែក អាជ្ញាធរសវនកម្មជាតិបានជ្រើសរើសយកក្រុង១ និងស្រុក៣ នៃខេត្តព្រៃវែង ក្នុងការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលក្នុងនោះមាន៖

- រដ្ឋបាលក្រុងព្រៃវែងមានទីលានចាក់សំរាមទំហំ ២,៨៤ ហិកតា នៅសង្កាត់បារាយណ៍ ក្រុងព្រៃវែង
- រដ្ឋបាលស្រុកពាមរក៍មានទីលានចាក់សំរាមទំហំ ១,៧ ហិកតា នៅឃុំបាបោង ស្រុកពាមរក៍ សម្រាប់បម្រើឱ្យការទុកដាក់សំរាមរបស់ស្រុកពាមរក៍
- រដ្ឋបាលស្រុកស្វាយអន្ទរមានទីលានចាក់សំរាមទំហំ ១,៦ ហិកតា ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ
- រដ្ឋបាលស្រុកកំពង់ត្របែកមានទីលានចាក់សំរាមទំហំ ១ ហិកតា ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក។

គោលបំណងនៃការធ្វើសវនកម្មនេះ ដើម្បីវាយតម្លៃថាតើ ខេត្តព្រៃវែងមានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់ខ្លួន ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាន និងចីរភាព ព្រមទាំងធានាបាននូវការចូលរួមចំណែកក្នុងការអនុវត្តនៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ ជាពិសេស ដើម្បីចូលរួមចំណែកការអនុវត្តគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅខេត្តព្រៃវែង ដោយគ្របដណ្តប់លើរដ្ឋបាលក្រុងព្រៃវែង រដ្ឋបាលស្រុកពាមរក៍ រដ្ឋបាលស្រុកស្វាយអន្ទរ និងរដ្ឋបាលស្រុកកំពង់ត្របែក សម្រាប់ការិយបរិច្ឆេទ២០២៥ និងឆ្នាំពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅតាមបណ្តារដ្ឋបាលក្រុង-ស្រុកខាងលើនេះ។

ជាលទ្ធផលបានបង្ហាញថា នាពេលបច្ចុប្បន្ននេះ រដ្ឋបាលខេត្តព្រៃវែងបានប្រឈមនឹងកង្វះទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់ខ្លួន ទាំងកង្វះទីលានទុកដាក់សំរាម សំណល់រឹងនៅតាមបណ្តារដ្ឋបាលក្រុង-ស្រុក ហើយទីលានខ្លះទៀតបានផ្ទុកសំរាមលើសពីសមត្ថភាពរបស់វា

ដែលតម្រូវឱ្យមានការសាងសង់ទីលានថ្មី។ បើទោះជាមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមរយៈការប្រជុំ ឬវេទិកាសាធារណៈក្តីក៏ប្រជាពលរដ្ឋមួយចំនួនដែលមានលំនៅដ្ឋានជាប្រភេទដីឡូត៍ធំៗនៅជាយក្រុង ស្រុក មិនបានប្រើប្រាស់សេវាសំរាមជាមួយក្រុមហ៊ុនធ្វើសេវាកម្មសំរាមឡើយ។ លើសពីនេះទៀត រដ្ឋបាលក្រុង រដ្ឋបាលស្រុកគ្មានវិធានការក្នុងផាកពិន័យអំពើល្មើសក្នុងការចោលសំរាមរាយប៉ាយតាមទីសាធារណៈ ហើយក្រុមហ៊ុនដែលទទួលសេវាធ្វើអាជីវកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក៏មិនបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យាឡើយ។

កត្តានេះ នាំឱ្យប៉ះពាល់ដល់សុវត្ថិភាពបរិស្ថាន សុខភាពសាធារណៈ និងសោភ័ណភាពនៃខេត្ត ក្រុង ស្រុក ដែលនាំឱ្យជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច ពីព្រោះថាសំរាមក៏ជាប្រភពនៃចំណូលផងដែរ ជាអាទិ៍ វាជាប្រភពនៃការកែច្នៃបង្កើតថាមពលអគ្គិសនី និងក៏ជាប្រភពនៃការកែច្នៃជីកំប៉ុស្តិ៍ទៀតផង និងជួយលើកកម្ពស់ដល់វិស័យទេសចរណ៍ និងបរិស្ថានស្អាតក្នុងដែនរដ្ឋបាលរបស់ខេត្ត។

តាមលទ្ធផលដែលបានបរិយាយក្នុងជំពូកទី៣ និងសេចក្តីសន្និដ្ឋានខាងក្រោម អាជ្ញាធរសវនកម្មជាតិសូមផ្តល់អនុសាសន៍ជូនរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តព្រៃវែងដូចខាងក្រោម ៖

(១) រដ្ឋបាលខេត្តព្រៃវែង ក្នុងនាមជាគណៈអភិបាលខេត្ត គួរជំរុញឱ្យរដ្ឋបាលក្រុង រដ្ឋបាលស្រុកទាំង៣ ខិតខំតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាការសម្អាត ប្រមូល និងដឹកជញ្ជូនរបស់ក្រុមហ៊ុនឱ្យបានច្បាស់លាស់។

(២) រដ្ឋបាលក្រុង-រដ្ឋបាលស្រុកទាំង៣ គួរជំរុញឱ្យក្រុមហ៊ុនខិតខំអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

(៣) រដ្ឋបាលខេត្តព្រៃវែងគួរណែនាំដល់រដ្ឋបាលក្រុង-រដ្ឋបាលស្រុកទាំង៣ ឱ្យបង្កើនការទទួលខុសត្រូវលើការគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន ព្រមទាំងបង្កើតនៅក្រុមការងារទទួលបន្ទុកពិន័យអន្តរការណ៍ចំពោះអំពើល្មើសការចោលសំរាមរាយប៉ាយតាមទីសាធារណៈ។

(៤) រដ្ឋបាលខេត្តព្រៃវែង ក្នុងនាមជាគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គួររួសរាន់ស្នើសុំឡើងវិញនូវផ្ទៃដីសម្រាប់រៀបចំធ្វើទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជននៅតាមបណ្តាក្រុង-ស្រុកគោលដៅមួយចំនួនដែលមិនទាន់មានទីលានទុកដាក់សំរាមជាផ្លូវការទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ស្របតាមប្លង់គោលរបស់រដ្ឋបាលខេត្តព្រៃវែង និងប្លង់គោលរបស់រដ្ឋបាលក្រុង-ស្រុកនីមួយៗ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តគួរខិតខំរិះរកមធ្យោបាយដើម្បីសាងសង់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមប្រភេទនៃទីលានសាមញ្ញមានការត្រួតពិនិត្យ។

(៥) រដ្ឋបាលក្រុង-រដ្ឋបាលស្រុកទាំង៣ នៃខេត្តព្រៃវែង គួរបង្កើននូវការផ្សព្វផ្សាយ និងណែនាំដល់សាធារណជនស្តីពីការញែក ការវេចខ្ចប់ និងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ព្រមទាំងរិះរកមធ្យោបាយក្នុងការជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមប្រើប្រាស់សេវាសំរាមឱ្យកាន់តែទូលំទូលាយតាមការកំណត់របស់ក្រសួងបរិស្ថាន។

(៦) រដ្ឋបាលក្រុង-រដ្ឋបាលស្រុកទាំង៣ គួររៀបចំផែនការប្រចាំឆ្នាំ និងផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការតាមដាន និងវាយតម្លៃការផ្តល់សេវារបស់ក្រុមហ៊ុន។

**មតិឆ្លើយតបរបស់រដ្ឋបាលខេត្តព្រៃវែង**

រដ្ឋបាលខេត្តព្រៃវែង សូមទទួលយកអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។ ហើយរដ្ឋបាលខេត្តព្រៃវែងនឹងខិតខំពង្រឹង និងជំរុញដល់រដ្ឋបាលក្រុង ស្រុកទាំង៣ ឱ្យកែលម្អនូវចំណុចខ្វះខាតទាំងឡាយនៅឆ្នាំបន្តបន្ទាប់ឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។